# របាយការណ៍

## ការចុះសំណេះសំណាលជាមួយថ្នាក់ដឹកនាំ នៅឃុំពោធិអង្រ្គង ឃុំពោធិចំរើន និង ឃុំទួលអំពិល ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ

នៅថ្ងៃសៅរ៍ ២រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី៣០ ខែមករា ឆ្នាំ២០២១

**ទីកន្លែង** : នៅទីស្នាក់ការគណបក្សប្រជាជនកម្ពុជាឃុំពោធិអង្រ្គង ពោធិចំរើន និងទួលអំពិល ក្នុងស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ។

**ក្រោមអធិបតីភាព** : ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា អនុប្រធានក្រុមការងារគណបក្សចុះជួយខេត្តកំពង់ស្ពឺ និងជាប្រធានក្រុមការងារគណបក្សចុះមូលដ្ឋានស្រុកបសេដ្ឋ បានអញ្ជើញចុះជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំមូលដ្ឋាន ដើម្បីធ្វើបច្ចុប្បន្នភាពសមាជិកបក្ស ពង្រឹងសាមគ្គីផ្ទៃក្នុង និងពង្រឹងសមាជិកបក្សឃុំ។

**សមាសភាពចូលរួម** : ពិធីនៅឃុំទាំង៣នេះមាន ការចូលរួមពីឯកឧត្តម លោកជំទាវ លោក អ្នកស្រី ជាអនុប្រធាន សមាជិកក្រុមការងារគណបក្សចុះមូលដ្ឋានស្រុកបសេដ្ឋ ប្រធាន អនុប្រធានក្រុមការងារគណបក្សចុះជួយឃុំ ប្រធានគណបក្សស្រុក ប្រធានគណបក្សឃុំ និងភូមិ សរុបប្រមាណ១៨០នាក់។

១.មតិបើក: ឯកឧត្តមប្រធានមានមតិស្វាគមន៍ និងថ្លែងអំណរគុណចំពោះសមាជិកដែលបានអញ្ជើញចូលរួម និងបានអនុញ្ញាតឱ្យប្រធានបក្សឃុំទាំង៣ឡើងធ្វើរបាយការណ៍បច្ចុប្បន្នភាព ជាពិសេសចំពោះស្ថានភាពទូទៅនៅក្នុងភូមិ ហើយបានអនុញ្ញាតឱ្យមេភូមិនីមួយៗរាយការណ៍ម្តងម្នាក់ៗ ក្នុងភូមិរៀងខ្លួន។ ក្នុងនោះ ផ្តោតសំខាន់លើ ទី១) ការបោះឆ្នោតក្រុមប្រឹក្សាឃុំ ទី២) ទប់ស្កាត់គណបក្សប្រឆាំង ទី៣) វិធានការការពារការចម្លងមេរោគអេដស៍ និងទី៤) វិធានការទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន។ លើសពីនេះទៅទៀត ឯកឧត្តម ក៏ស្នើឱ្យលើកឡើងពីចំណុចអសកម្មដែលកើតមានឡើង ព្រមទាំងបញ្ហាដែលជាឧបសគ្គ និងសំណូមពរផងដែរ។

២. របាយការណ៍ :

ក)- ស្ថានភាពទូទៅ ឃុំពោធិអង្រ្គង ៖

- ឃុំមាន១៩ ភូមិ មាន៤,២៥៧ គ្រួសារ គ្រួសារបក្សមានចំនួន៣,១៣១ ស្មើនឹង៧៣.៥៤%។
- ប្រជាជនសរុបចំនួន១៨,៦៤៩ នាក់ (ស្រី៩,៤០៦)។
- ប្រជាជនដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត គ.ជ.ប ចំនួន១១,០១៤នាក់(ស្រី៦,០៣២)។
- ប្រជាជនដែលមានអាយុចាប់ពី១៨ឆ្នាំឡើងមានចំនួន១២,២៧៩នាក់ (ស្រី៦,៥៥៧)។
- សមាជិកបក្សបច្ចុប្បន្នភាពមានឈ្មោះក្នុងបញ្ជីបោះឆ្នោត គ.ជ.ប ចំនួន៧,៦៣៤នាក់ ស្មើនឹង ៦២.១៧% នៃប្រជាជន១៨ឆ្នាំឡើង ស្មើនឹង៦៩.៣១% នៃប្រជាជនមានឈ្មោះក្នុងបញ្ជីបោះឆ្នោត។
- ចំនួនប្រជាពលរដ្ឋចំណាកស្រុក ក្នុងស្រុកចំនួន ៧៨៣នាក់ កម្មកររោងចក្រ៣,៤៥៩នាក់
- ចំនួនកម្មករចំណាកស្រុកក្រៅប្រទេស១៤៨នាក់ បានណែនាំឱ្យធ្វើចត្តាឡីស័ក។

- ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋបានទាន់ពេលវេលា មានដូចជា អត្រានុកូលដ្ឋាន និងលិខិតស្នាមផ្សេងៗ។
- សកម្មភាពក្រុមការងារគណបក្ស គឺបានចុះជាប់ជាប្រចាំតាមមូលដ្ឋានភូមិ ឃុំ ក្នុងការពង្រឹងសមាជិកបក្ស ផ្សព្វផ្សាយគោលនយោបាយរបស់បក្ស។
- ដោះស្រាយរាល់បញ្ហាបាតុភាពផ្សេងៗ និងដោះស្រាយតាមលទ្ធភាពជូនប្រជាជនក្រីក្រ និងជនងាយរងគ្រោះនៅក្នុងមូលដ្ឋាន។
- រចនាសម្ព័ន្ធអង្គការចាត់តាំងគណបក្សរួមមាន ៖ គណៈកម្មាធិការបក្ស២៧នាក់ (ស្រី២នាក់) ក្រុមប្រឹក្សាឃុំ ១១នាក់ (ស្រី២នាក់) ជំនួយការឃុំ៣នាក់ សាខាបក្សចំនួន២៥ អនុសាខាចំនួន៦៣ និងក្រុមបក្សចំនួន៣១៣១។
- **ការអភិវឌ្ឍន៍ភូមិ ឃុំ ៖** មានកសិដ្ឋានចិញ្ចឹមសត្វ២៣កន្លែង

ខ)- ស្ថានភាពទូទៅ ឃុំពោធិចំរើន ៖

- ឃុំមាន១៤ ភូមិ មាន២,២០៨គ្រួសារ គ្រួសារបក្សមានចំនួន១,៩២៣ ស្មើនឹង៨៧.០៩%។
- ប្រជាជនសរុបចំនួន៩,៤៤១ នាក់ (ស្រី៥,១៨៤)។
- ប្រជាជនដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត គ.ជ.ប ចំនួន៥,៥៣២នាក់(ស្រី២,៩៩២)។
- ប្រជាជនដែលមានអាយុចាប់ពី១៨ឆ្នាំឡើងមានចំនួន៦,០០៩នាក់ (ស្រី៣,២៧៧)។
- សមាជិកបក្សបច្ចុប្បន្នភាពមានឈ្មោះក្នុងបញ្ជីបោះឆ្នោត គ.ជ.ប ចំនួន៤,៦៦០នាក់ ស្មើនឹង៧៧.៥៥% នៃប្រជាជន១៨ឆ្នាំឡើង ស្មើនឹង៨៤.២៤% នៃប្រជាជនមានឈ្មោះក្នុងបញ្ជីបោះឆ្នោត។
- រចនាសម្ព័ន្ធអង្គការចាត់តាំងគណបក្សរួមមាន ៖ គណៈកម្មាធិការបក្ស២១នាក់ ក្រុមប្រឹក្សាឃុំ ០៧នាក់ ជំនួយការឃុំ២នាក់ សាខាបក្សចំនួន២០ អនុសាខាចំនួន៤២ និងក្រុមបក្សចំនួន១៩២៣។

គ)- ស្ថានភាពទូទៅ ឃុំទួលអំពិល ៖

- ឃុំមាន១៥ ភូមិ មាន៣,២០២គ្រួសារ គ្រួសារបក្សមានចំនួន២,៣១១ ស្មើនឹង៧២.១៧%។
- ប្រជាជនសរុបចំនួន១២,៣២៧ នាក់ (ស្រី៦,៥៥៣)។
- ប្រជាជនដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត គ.ជ.ប ចំនួន៧,៤៧៩នាក់(ស្រី៤,១៦៨)។
- ប្រជាជនដែលមានអាយុចាប់ពី១៨ឆ្នាំឡើងមានចំនួន៨,៣០៥នាក់ (ស្រី៤,៤៦៤)។
- សមាជិកបក្សបច្ចុប្បន្នភាពមានឈ្មោះក្នុងបញ្ជីបោះឆ្នោត គ.ជ.ប ចំនួន៥,៧០៣នាក់ ស្មើនឹង៦៨.៦៦% នៃប្រជាជន១៨ឆ្នាំឡើង ស្មើនឹង៧៦.២៥% នៃប្រជាជនមានឈ្មោះក្នុងបញ្ជីបោះឆ្នោត។
- រចនាសម្ព័ន្ធអង្គការចាត់តាំងគណបក្សរួមមាន ៖ គណៈកម្មាធិការបក្ស២១នាក់ ក្រុមប្រឹក្សាឃុំ០៧នាក់ ជំនួយការឃុំ២នាក់ សាខាបក្សចំនួន១៩ អនុសាខាចំនួន៤៥ និងក្រុមបក្សចំនួន២៣១១។

បញ្ហាប្រឈមដែលកើតមានក្នុងភូមិ ដូចជា ៖

- មានការអូសទាញប្រជាពលរដ្ឋក្នុងភូមិឱ្យចងការប្រាក់ ដោយផ្តល់នូវការប្រាក់ខ្ពស់។

- មេការប្រាក់២នាក់ នៅតែមានសេរីភាព មិនទាន់មានការសងការប្រាក់តាមកិច្ចសន្យា ហើយបន្តការសាងសង់ផ្ទះ។
- ប្រជាពលរដ្ឋបានដាក់ពាក្យបណ្តឹងជាច្រើនដង ប៉ុន្តែមិនទាន់មានចំណាត់ការពីតុលាការ។
- ពលករចំណាកស្រុកក្នុងស្រុក និងក្រៅប្រទេស មានចេញ ចូលជាបន្តបន្ទាប់។

**សំណូមពរមានដូចជា ៖**

- សូមឱ្យអាជ្ញាធរមានចំណាត់ការលើមេការប្រាក់តាមនីតិវិធីច្បាប់ឱ្យបានឆាប់។
- ស្នើសុំបញ្ចូលជាសមាជិកក្រុមការងារគណបក្សចុះជួយឃុំពោធិចំរើន និងឃុំពោធិអង្ក្រង។
- សូម ឯកឧត្តមប្រធានក្រុមការងារគណបក្សចុះជួយស្រុកបសេដ្ឋ មេត្តាជួយរកយុត្តិធម៌ និងពន្លឿនចំណាត់ការជូនពួកគាត់ផង។

**៣.ការពិភាក្សា** : ឯកឧត្តមទេសរដ្ឋមន្ត្រី បានទទួលយកនូវសំណូមពរទាំងអស់ពីប្រធានភូមិ ដើម្បីយកទៅ

ពិនិត្យ និងដោះស្រាយជាមួយក្រុមការងារចុះជួយស្រុកបសេដ្ឋ។

- មេឃុំ រៀបចំរបាយការណ៍ទាក់ទងទៅនឹងមេការ ចងការប្រាក់ខ្ពស់ជូន ឯកឧត្តមប្រធានក្រុមការងារចុះជួយស្រុកបសេដ្ឋ។
- នៅក្នុងភូមិមានសាខាលក់ផលិតផលសម្អាង និងអាហារបំប៉នជាច្រើន សូមពិនិត្យឡើងវិញ និងតាមដានសកម្មភាពសាខាលក់ផលិតផលសម្អាង និងអាហារបំប៉នក្នុងភូមិ។
- ឯកឧត្តមប្រធាន បានឯកភាពក្នុងការស្នើសុំបញ្ចូលជាសមាជិកក្រុមការងារគណបក្សចុះជួយឃុំទាំងពីរ

៤.សេចក្តីសម្រេច (ការផ្តល់អនុសាសន៍)៖

យើងមានការផ្អាកការជួបប្រជុំមួយរយៈ ដោយសារកូវីដ-១៩។ ប៉ុន្តែ ឯកឧត្តម លោកជំទាវ ក្រុមការងារ និងអាជ្ញាធរស្រុក ឃុំ បានបន្តការងារ ព្រមទាំងធ្វើឱ្យមានការរីកចម្រើន និងការអភិវឌ្ឍជាបន្តបន្ទាប់។ ដូច្នេះ សូមសរសើរក្រុមការងារដែលបានធ្វើកន្លងមក។ យើងនៅមិនទាន់ដឹងថា ស្ថានភាពកូវីដនឹងធូរស្រាលនៅពេលណាទេ។ ប៉ុន្តែ ក្រោមការដឹកនាំរបស់សម្តេចតេជោ ប្រទេសយើងគ្រប់គ្រងសភាពការណ៍បានជោគជ័យដោយសារមានវិន័យ ពាក់ម៉ាស លាងដៃ និងគោរពតាមវិធីការពារដែលមានប្រសិទ្ធភាព។ មន្ត្រីមូលដ្ឋានតាមដាន ក្តាប់ជាប់ និងធ្វើចត្តាឡីស័កត្រឹមត្រូវ។ នៅឆ្នាំ២០២២ យើងសង្ឃឹមថាសភាពការណ៍នឹងវិលត្រឡប់ទៅរកសភាពធម្មតាវិញ។ ប៉ុន្តែនៅពេលនេះយើងត្រូវបន្តវិធានការសុខាភិបាលបន្តទៀត (៣ការពារ និង ៣កុំ)។

ដរាបណានៅតែមានកូវីដ-១៩ យើងនៅតែមានបញ្ហាខាង សេដ្ឋកិច្ច ជាពិសេស វិស័យទេសចរណ៍នៅតែមានការលំបាក។ ដូច្នេះ យើងត្រូវត្រៀមផលប៉ះពាល់សេដ្ឋកិច្ច ក្នុងលក្ខខណ្ឌថា រដ្ឋមិនកាត់បន្ថយថវិកាទេ តែត្រូវមានការសន្សំសំចៃ។ ប្រទេសយើងនៅទប់ទល់បាន ក្នុងឆ្នាំ២០២០កន្លងទៅការនាំចេញ នាំចូលមានប្រមាណ ៣០ពាន់លានដុល្លារ។

ជាមួយគ្នានោះ ឯកឧត្តមទេសរដ្ឋមន្ត្រី បានលើកជាសំណួរថា តើបច្ចុប្បន្ននេះ យើងមានការរីកចម្រើនអ្វីខ្លះ? យើងមានមាសតម្កល់ទុក៥៤តោន។ យើងសង្ឃឹមថានៅឆ្នាំ២០៣០ យើងនឹងប្រែក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់។ ហើយនៅឆ្នាំ២០៥០ យើងនឹងក្លាយជាប្រទេសចំណូលខ្ពស់។

ឯកឧត្តមទេសរដ្ឋមន្ត្រី ក៏បានសង្កត់បញ្ជាក់ថា បានជាយើងមានការរីកចម្រើន គឺដោយសារមានសុខសន្តិភាព។ បើគ្មានសន្តិភាពទេ យើងមិនអាចធ្វើការអភិវឌ្ឍន៍ និងមានការរីកចម្រើនឡើយ។ គោលនយោបាយរបស់យើង គឺពង្រឹងសន្តិភាព។

ឯកឧត្តម ក៏បានបញ្ជូនសារថា សព្វថ្ងៃនៅមានអ្នកនៅសង្ឃឹមថា បក្សសង្គ្រោះជាតិរស់ឡើងវិញ ត្រង់ចំណុចនេះគឺមិនអាចទៅរួចទេ ពួកគេមានតែបង្កើតគណបក្សថ្មីទេ។ សូមអ្នកទទួលខុសត្រូវក្នុងភូមិ ប្រាប់អ្នកដែលនៅរង់ចាំថាទៅមិនរួចទេ។ គេចោទថា កុំម្មុយនីស្ត តែក្រោយឆ្នាំ១៩៩៣ យើងប្រែក្លាយជាពហុបក្សហើយ។ ប្រទេសកម្ពុជា មិនមែនឯកបក្សទេ ប៉ុន្តែបោះឆ្នោតជាប់តែ១បក្ស មិនអាចទៅបន្ទោសប្រជាជនទេ។ យើងបោះឆ្នោត៥ឆ្នាំម្តង ដោយសាររដ្ឋធម្មនុញ្ញតម្រូវឱ្យប្រជាពលរដ្ឋសម្តែងមតិ។ យើងមានចេតនាកាន់អំណាច ដោយមានការគាំទ្រពីប្រជាជន ដោយបម្រើប្រជាជន និងយកប្រជាជនជាធំ។

គោលបំណងនៃការជួបប្រជុំគ្នានៅថ្ងៃនេះ គឺយើងចង់យល់ដឹងអំពីការគ្រប់គ្រងសមាជិកបក្សរបស់យើង។ ការធ្វើបច្ចុប្បន្នភាពសមាជិកបក្ស តើបានដល់ណាហើយ? តើមានការផ្ទៀងផ្ទាត់ចំនួនសមាជិកបក្ស និងបញ្ជីគ.ជ.ប ច្បាស់លាស់ដែរឬទេ? ជាមួយគ្នានោះ ឯកឧត្តមទេសរដ្ឋមន្ត្រីបានណែនាំសមាជិកដែលចូលរួមក្នុងកិច្ចប្រជុំថា យើងត្រូវក្តាប់សមាជិកបក្សឱ្យបានច្បាស់ និងត្រូវត្រៀមខ្លួនពីឥឡូវ។ ក្នុងនោះដែរ យើងក៏ត្រូវពិនិត្យមើលសមាសភាពក្រុមប្រឹក្សាឃុំរបស់យើងថា តើមានប្រសិទ្ធភាពឬទេ? ត្រូវធ្វើការកែសម្រួលដែរឬទេ? បើមានសមាជិកដែលចាស់ពេក ហើយចង់ឈប់ ត្រូវរកអ្នកជំនួស? ប៉ុន្តែ បើមេឃុំ ឬសមាជិកក្រុមប្រឹក្សាថា នៅមានកម្លាំង និងមានការគាំទ្រពីប្រជាជនត្រូវលើកទឹកចិត្តគាត់ឱ្យបន្ត។ ក្នុងរយៈពេល ១៤ខែខាងមុខ យើងត្រូវត្រៀមលក្ខណៈ ដើម្បីយកការគាំទ្រពីប្រជាជន។

ចំពោះបញ្ហាជំងឺអេដស៍ ឯកឧត្តមទេសរដ្ឋមន្ត្រីបានថ្លែងនូវការបារម្ភអំពីការផ្ទុះឡើងវិញ ជាពិសេសក្នុងចំណោមយុវវ័យអាយុតិចជាង៣០ឆ្នាំ។ ក្រុមយុវវ័យនេះមួយចំនួនមានប្រពន្ធ និងមានប្តីផង ដែលបច្ចុប្បន្នមានប្រមាណ៩ម៉ឺននាក់។ ដើម្បីចូលរួមប្រយុទ្ធនឹងជំងឺអេដស៍ ឯកឧត្តមស្នើសុំ ឃុំចាត់ជំនួយការ១នាក់ធ្វើការងារអេដស៍។ ជាមួយគ្នានេះ ឃុំត្រូវបង្កើតគណៈកម្មការអេដស៍ឃុំ ដោយសមាសភាពមកពី គណៈកម្មការកិច្ចការនារី និងកុមារ មណ្ឌលសុខភាព អង្គការសុខភាពឬអេដស៍ និងអ្នកដែលពូកែឃោសនា និងមានឥទ្ធិពលក្នុងឃុំ។ សាលាស្រុកបសេដ្ឋនឹងរៀបចំកម្មវិធីមួយ អញ្ជើញឃុំធ្វើការងារលម្អិតរឿងនេះ។ ហើយខ្ទង់ចំណាយដែលអាចយកមកធ្វើការ គឺខ្ទង់សេវាសង្គម។ ការងារអេដស៍ដែលមូលដ្ឋានត្រូវធ្វើ មានការពិនិត្យមើលថា អ្នកជំងឺមានទៅទទួលសេវា លេបថ្នាំទៀងទាត់ និងមានបណ្ណក្រីក្រដែរឬទេ? តើកូនៗគាត់បានទទួលការអប់រំដែរឬទេ?

យើងត្រូវអប់រំយុវវ័យឱ្យចេះបង្ការការចម្លង ដោយការប្រើស្រោមអនាម័យ ធ្វើតេស្តឈាម បើមានការសង្ស័យថាឆ្លងមេរោគអេដស៍។ ពេលមានយន្តការហើយនោះ យើងនឹងទៅនិយាយជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យទម្លាក់លុយមកជួយ។

នៅទីបញ្ចប់ ឯកឧត្តមទេសរដ្ឋមន្ត្រីបានផ្តាំថា ៖

១) ឆ្នាំ២០២២ ជាឆ្នាំនៃការតេស្តបញ្ជាក់មើលសមត្ថភាព យើងត្រូវជោគជ័យបន្តទៀត។ ដូច្នេះ សូមសហការគ្នាឱ្យបានជោគជ័យដ៏ត្រចះត្រចង់។

២) ត្រូវយកចិត្តទុកដាក់សកម្មភាពគណបក្សផ្សេងៗ ក៏ដូចជា សកម្មភាពក្រុមបោកប្រាស់ប្រជាពលរដ្ឋដែលខ្ចីប្រាក់ឱ្យការខ្ពស់ និងបណ្តាញលក់ផលិតផលជាដើម។

៣) នៅក្នុងឃុំ មេឃុំធំជាងគេ ដូច្នេះស្មៀនត្រូវពន្លឿនការបោះត្រា និងត្រូវយកត្រាមកទុកនៅសាលាឃុំ។

៤) យើងជាមន្ត្រីគណបក្សប្រជាជនត្រូវបម្រើប្រជាជន និងផ្តល់សេវាសាធារណៈល្អ។ ពីថ្ងៃនេះទៅមុខខំធ្វើឱ្យមានការគាំទ្រពីប្រជាជន។ បើមេឃុំមានការងារខាងក្រៅ មិននៅសាលាឃុំត្រូវសរសេរលើក្តារខៀន ដើម្បីផ្តល់ដំណឹង ឬដាក់លេខទូរស័ព្ទ ដែលជាការ សម្រួលដល់ការមករកសេវារបស់ប្រជាពលរដ្ឋ។

ថ្ងៃសៅរ៍ ២រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២១

បានឃើញ និងឯកភាព
ប្រធានក្រុមការងារចុះជួយស្រុកបសេដ្ឋ

អៀង_មូលី

អ្នកធ្វើកំណត់ហេតុ

ស៊ុត_ថនផាន់